រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
គណៈកម្មាធិការវិនិយោគកម្ពុជា
Cambodian Investment Board
លេខ ៤៥៩៨/១៧ គ.វ.ក

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation- Religion- King

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៧

## ជម្រាបជូន
## លោកប្រធានក្រុមហ៊ុន
## "YONGHENGXING LEATHER (CAMBODIA) CO., LTD."

**កម្មវត្ថុ :** ករណីសំណើសុំវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ។

**យោង :**
- ពាក្យសុំវិនិយោគនាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧
- ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០៣. នស.៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌលេខ ៤៤០៩/១៧ គ.វ.ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា"គណៈកម្មាធិការវិនិយោគកម្ពុជា"
- ចំណារឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស អនុប្រធាន "ក.អ.ក" ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានជ្រាបថា ៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា"គណៈកម្មាធិការវិនិយោគកម្ពុជា" បានសម្រេចចេញ**វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ** នូវគម្រោងបង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" នៅ"ក.អ.ក" ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ស្របតាមខ្លឹមសារដូចខាងក្រោម :

- នាមករណ៍ក្រុមហ៊ុន : យ៉ុងហេងស៊ីង លេឌើរ (ខេមបូឌា) ឯ.ក
  YONGHENGXING LEATHER (CAMBODIA) CO., LTD.
- ទីស្នាក់ការក្រុមហ៊ុន : ភូមិរំដួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។
- ទីតាំងវិនិយោគ : ភូមិរំដួល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។
- ទុនវិនិយោគ : ៥.៥២២.០០៦ USD (ប្រាំលានប្រាំរយម្ភៃពីរពាន់ប្រាំមួយដុល្លារអាមេរិក)។

ទន្ទឹមនឹងនេះ ក្រុមហ៊ុនលោកត្រូវ :
- អនុវត្តឲ្យបានត្រឹមត្រូវតាមបណ្តាលក្ខខណ្ឌដែលមានចែងក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ។
- លើកសំណើសុំនាំចូលដោយរដ្ឋជាអ្នកទទួលបន្ទុកលើពន្ធនាំចូល តាមទម្រង់ CIB01E ដូចមានជូនភ្ជាប់មកជាមួយនេះជាមុនសិន ទើប ក.អ.ក/គ.វ.ក ពិនិត្យសម្រេចជាក្រោយ។
- មានកាតព្វកិច្ចធ្វើរបាយការណ៍ស្តីពី :
  . សារពើពន្ធដូចបានកំណត់ក្នុងមាត្រា១០៤ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ចាប់ពីថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ដោយដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ សម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់ តាម

បទប្បញ្ញត្តិនៃពន្ធនីមួយៗ ជូនអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ច ចំពោះរដ្ឋសម្រាប់ឆ្នាំសារពើពន្ធ។

. ការលើកលែងពន្ធគយ នូវរាល់សម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់ ដែលបាននាំចូលក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការក្រោយការនាំចូល មក ក.អ.ក និងអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លង ដែលមានការបញ្ជាក់ត្រឹមត្រូវលើឯកសារបំពេញបែបបទគយ ក្នុងនោះមានទាំងឯកសារបញ្ជាក់តម្លៃទំនិញ ពីភ្នាក់ងារដែលរាជរដ្ឋាភិបាលបានជ្រើសតាំងឲ្យទទួលភារកិច្ចផង។

. ហិរញ្ញវត្ថុប្រចាំឆ្នាំរួមមាន : តារាងតុល្យការ របាយការណ៍លទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ ដោយមិនឲ្យហួសពីថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ជូនមក ក.អ.ក។

. ការបំពេញកាតព្វកិច្ចសារពើពន្ធ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ មក ក.អ.ក ដែលបញ្ជាក់ថា អ្នកវិនិយោគបាន :

+បំពេញត្រឹមត្រូវ និងដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែគ្រប់គ្រាន់ ទាន់ពេលវេលា លើកលែងតែលិខិតប្រកាសប្រចាំឆ្នាំនោះ ដែលតម្រូវដោយច្បាប់ស្តីពីសារពើពន្ធ។

+បង់ពន្ធទាំងអស់ ប្រាក់ពន្ធ ការប្រាក់ និងប្រាក់ពន្ធបន្ថែម ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធ ព្រមទាំងបានធ្វើសវនកម្មរួច ដោយអគ្គនាយកដ្ឋានពន្ធដារ។

. ការនាំចូលជាក់ស្តែងប្រចាំត្រីមាស នូវសម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបម្រើឲ្យផលិតកម្ម និងការនាំចេញជាក់ស្តែងប្រចាំត្រីមាស នូវផលិតផលសម្រេច ព្រមទាំងតារាងអចលនទ្រព្យប្រចាំឆ្នាំ។

. បញ្ជីអង្កេតព័ត៌មានវិនិយោគទម្រង់ CIB 01S។

អាស្រ័យហេតុនេះ សូមលោកប្រធានអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ តាមការណែនាំដូចរៀបរាប់ខាងលើនេះ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គលេខាធិការ**

**សុខ ចិន្តាសោភា**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស អនុប្រធាន "ក.អ.ក"
- ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី** ប្រធាន "ក.អ.ក"
- សាលាខេត្តកំពង់ស្ពឺ
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ-កាលប្បវត្តិ